# សិក្ខាសាលា

## ធ្វើនៅទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា
## ចាប់ពីថ្ងៃទី ១០ ដល់ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២៤

## ការរៀបចំទីក្រុងភ្នំពេញឡើងវិញ៖ ការប្រើប្រាស់ទម្រង់បែបបទសំណង់ និង ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ជាវត្ថុតាង

### អំពីសិក្ខាសាលា

ក្នុងអំឡុងសតវត្សទី ២០ ទីក្រុងភ្នំពេញ បានទទួលរងការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដែលរួមមាន ការពង្រីកទីក្រុង ការធ្វើទំនើបកម្ម សង្គ្រាម ការលុបបំបាត់នគរូបនីយកម្ម ការធ្វើរូបនីយកម្មឡើងវិញ រួមទាំងមានកំណើនប្រជាជន និងគម្រោងអភិវឌ្ឍន៍នានាជាច្រើន ជាពិសេសនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រវត្តិកាលរបស់រាជធានីភ្នំពេញ បានឆ្លុះបញ្ចាំងអំពីកំណែទម្រង់វិស័យនយោបាយ និងសង្គម នៅកម្ពុជា ចាប់តាំងពីប្រទេសនេះទទួលបានឯករាជ្យមក។ សិក្ខាសាលានេះ នឹងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រជំនាន់ថ្មី តាមរយៈការសិក្សាលើការធ្វើនគរូបនីយកម្មទីក្រុង ដោយមានការផ្តោតសំខាន់លើការរៀបចំឬប្រើប្រាស់ឡើងវិញ នៃសំណង់អគារនិងហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ ទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធការពារជាតិ នៅទីក្រុងភ្នំពេញ ចាប់តាំងពីអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ៥០ រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ៩០។ សិក្ខាសាលានេះ មានគោលបំណងរួម ២ ធំៗ ទីមួយគឺ ដើម្បីស្វែងយល់ពីលទ្ធផលនៃសង្គ្រាម ការផ្លាស់ប្តូររបប និងការផ្លាស់ប្តូរនយោបាយ ដែលធ្វើឱ្យមានការលេចឡើងនូវបម្រែបម្រួលហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុង និងទី២ គឺដើម្បីបង្កើតឱ្យមានការសិក្សាស្រាវជ្រាវកាន់តែលម្អិត ឬជិតដិតអំពីហេតុការណ៍ប្រវត្តិសាស្ត្រ។ តាមរយៈការប្រើប្រាស់ទម្រង់បែបបទសំណង់និងហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ជាវត្ថុតាង នឹងផ្តល់នូវការវិភាគគម្រោងដែលប្រកបដោយភាពជាក់លាក់ និងភាពច្នៃប្រឌិត។ តាមរយៈការសិក្សាអំពីស្ថាបត្យកម្ម ដែលមានស្រាប់ ឬមិនទាន់មាន ដែលបានកែច្នៃប្រើប្រាស់ឡើងវិញ ឬមិនទាន់បានកែច្នៃឡើងវិញ ដោយរដ្ឋាភិបាល សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលនីមួយៗ និងស្ថាបត្យកម្មដែលបានបន្សល់ទុករហូតមកដល់ថ្ងៃនេះ ទោះបីនៅក្រោមស្ថានភាពបែបណាក៏ដោយ។ យើងនឹងព្យាយាមបង្កើតនូវគំនូសតាងប្រវត្តិសាស្ត្រនៃទីក្រុងភ្នំពេញ និងប្រជាជនដែលរស់នៅក្នុងទីក្រុងនេះ ក្នុងរយៈពេលជាង ៤ ទសវត្សរ៍កន្លងមក ដោយមើលទៅលើសម្ភារៈសង្គម និងការប្រើប្រាស់អភិក្រមពីក្រោមឡើងលើ (Bottom-up Approach)។

## តើសិក្ខាសាលានេះនឹងផ្តោតលើអ្វីខ្លះ?

សិក្ខាសាលានេះ មានគោលបំណងផ្តល់ឱ្យសិក្ខាកាមដែលចូលរួមនូវជំនាញចាំបាច់ សម្រាប់ប្រើប្រាស់ក្នុងអាជីពវិជ្ជាជីវៈដែលទាក់ទងនឹងការស្រាវជ្រាវ ការធ្វើបទបង្ហាញ ការធ្វើការតាក់តែង និងការបោះពុម្ពផ្សាយ។ មូលដ្ឋាននៃសិក្ខាសាលានេះនឹងផ្អែកលើសកម្មភាពអនុវត្តដោយផ្ទាល់។ អ្នកចូលរួមនឹងស្វែងយល់ពីវិធីផ្សេងៗនៃការរក្សានិង ការប្រើប្រាស់បណ្ណសារ និងមានការចូលរួមរបស់ទស្សនិកជនគ្រប់មជ្ឈដ្ឋាន។ អ្នកចូលរួមនឹងតម្រូវឱ្យបង្កើតគម្រោង ក្នុងប្រធានបទទាក់ទងនឹងសំណង់និងហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុងភ្នំពេញ។ គម្រោងនោះអាចជារូបថត ឬស៊េរីរូបថត (ដោយមានឬគ្មានអត្ថបទ) ការសម្តែងវីដេអូខ្លី ការសម្តែងដោយប្រើប្រាស់សម្លេង ការតាំងពិព័រណ៍តូចមួយ វត្ថុតាំង មាតិកាក្នុងបណ្តាញសង្គម ឬគម្រោងអ្វីមួយ តាមគំនិតច្នៃប្រឌិតរបស់សិក្ខាកាម ដោយប្រើប្រាស់ធនធាន ដែលយើងនឹងសិក្សាស្វែងរករួមគ្នាមានដូចជា សំណង់ រូបថត ខ្សែភាពយន្ត ឯកសារ សារព័ត៌មាន រូបគំនូរផ្សេងៗ ។ល។ ក្នុងអំឡុងការសិក្សានេះ អ្នកនឹងត្រូវបានដឹកនាំដោយវាគ្មិនជាច្រើនដូចជា Khvay Samnang (សិល្បករ) Vuth Lyno (សិល្បករ) លោកស្រី Stephanie Benzaquen-Gautier (ប្រវត្តិវិទូ) Fabienne Luco (នរវិទូផ្នែកសង្គមវិទ្យា)និង Anne-Laure Porée (នរវិទូ) ហើយពួកគេនឹងណែនាំ និងបណ្តុះបណ្តាលសិក្ខាកាមនូវវិធីសាស្ត្រស្រាវជ្រាវបែបអន្តរកម្មសិក្សា។ នៅថ្ងៃចុងក្រោយនៃសិក្ខាសាលា នឹងមានព្រឹត្តិការណ៍សាធារណៈ នៅមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ដែលសិក្ខាកាមនឹងធ្វើបទង្ហាញពីគម្រោង របស់ខ្លួនទៅកាន់ទស្សនិកជនដែលចូលរួម។ បន្ថែមពីនេះ សកម្មភាពសិក្ខាសាលានឹងត្រូវបានផ្សព្វផ្សាយ តាមរយៈការបោះពុម្ពផ្សាយ និងតាមបណ្តាញសង្គមនានា។

ភាសាគោលដែលប្រើប្រាស់នៅក្នុងសិក្ខាសាលានេះ គឺភាសាខ្មែរ។

## តើសិក្ខាសាលានេះនឹងប្រព្រឹត្តទៅយ៉ាងដូចម្តេច?

សិក្ខាសាលានឹងប្រព្រឹត្តទៅរយៈពេលប្រាំថ្ងៃ នៅកន្លែងជាច្រើនក្នុងរាជធានីភ្នំពេញ ដូចជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងស្ថាប័នបណ្ណសារនានានៅរាជធានីភ្នំពេញ។ សេចក្តីសង្ខេប នាព្រឹកថ្ងៃដំបូង (ពីម៉ោង ៨ ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់) នឹងមានការធ្វើបទបង្ហាញពីវាគ្មិន អំពីកិច្ចការសិក្សាស្រាវជ្រាវ និងពិភាក្សាអំពីវិធីសាស្ត្រស្រាវជ្រាវរបស់ពួកគេ។ វាគ្មិននឹងពន្យល់លម្អិតអំពីសិក្ខាសាលា ដោយរួមបញ្ចូលនឹងមតិយោបល់របស់សិក្ខាកាម និងឆ្លើយតបទៅនឹងសំណួររបស់សិក្ខាកាម។ នៅព្រឹកបន្ទាប់ៗ សិក្ខាកាមនឹងត្រូវបានដឹកនាំទៅទស្សនាសំណង់អគារ (ព្រឹកថ្ងៃទី២) និងការសិក្សាអនុវត្តផ្ទាល់នៅស្ថាប័នបណ្ណសារនានា (ព្រឹកថ្ងៃទី៣ និងទី៤)។ នៅក្នុងការចុះកម្មសិក្សានៅស្ថាប័នទាំងនោះ បុគ្គលិក និងបណ្ណារក្សនៃស្ថាប័ននីមួយៗ នឹងណែនាំសិក្ខាកាមឱ្យស្គាល់នូវ សមុច្ច័យរបស់ពួកគេ ព្រមទាំងផ្តល់ជំនួយក្នុងការស្វែងរកឯកសារស្រាវជ្រាវ។

ចំណែកឯនៅពេលរសៀលនៃសិក្ខាសាលាទាំងមូល (ចាប់ពីម៉ោង ១:៣០ នាទី ដល់ម៉ោង ៥:៣០ នាទីរសៀល) សិក្ខាកាមនឹងតែម្រូវឱ្យចំណាយពេលរៀបចំ និងបង្កើតគម្រោងរបស់ខ្លួន។ សិក្ខាកាមនឹងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់បន្ទប់រួម នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រសិនបើចាំបាច់។

សិក្ខាសាលានឹងមានការបើកជាសាធារណៈ "គោលនយោបាយបើកចំហរ" មានន័យថា ភ្ញៀវទស្សនា (សិល្បករ អ្នកស្រាវជ្រាវ ឬអ្នកជំនាញ) អាចទៅធ្វើការទស្សនាក្រៅផ្លូវការ និងធ្វើការពិភាក្សាជាមួយសិក្ខាកាមអំពីគម្រោងរបស់ខ្លួន។

នៅថ្ងៃចុងក្រោយនៃសិក្ខាសាលា ព្រឹត្តិការណ៍ជាសាធារណៈនេះនឹងត្រូវបានបែងចែកជា ២ ផ្នែក៖
១) ការធ្វើបទបង្ហាញអំពីគម្រោងរបស់សិក្ខាកាម
២) កិច្ចពិភាក្សាតុមូល ដែលសិក្ខាកាមនឹងត្រូវបានអញ្ជើញចូលរួមពិភាក្សាជាមួយនឹងវាគ្មិនផ្ទាល់។

លើសពីនេះទៅទៀត វិទ្យាស្ថានអន្តរជាតិសិក្សាពីអាស៊ី (IIAS) នៃសាកលវិទ្យាល័យឡៃដិន University of Leiden បានស្នើសុំឱ្យមានការដាក់បញ្ចូល និងបោះពុម្ពផ្សាយអំពីសិក្ខាសាលាក្នុងព្រឹត្តិបត្ររបស់សាកលវិទ្យាល័យ (https://www.iias.asia/the-newsletter) ដែលមានអ្នកអានជុំវិញពិភពលោករហូតដល់ទៅ ៥៥,០០០ នាក់។

សិក្ខាកាមនឹងត្រូវរៀបចំឯកសារ នៃគម្រោងដោយខ្លួនឯង ដែលរួមមាន ប្រធានបទ រចនាសម្ព័ន្ធ គំនូរបង្ហាញ និងសរសេររៀបរាប់អំពីគម្រោងរបស់ខ្លួន សម្រាប់ការបោះពុម្ពផ្សាយនេះ។ ក្រុមអ្នកជំនាញនិង វាគ្មិនដែលចូលរួមក្នុងសិក្ខាសាលា នឹងផ្តល់ជាជំនួយក្នុងការធ្វើទម្រង់ក្របខ័ណ្ឌ (ការរៀបចំប្រធានបទនៃសិក្ខាសាលា ការពន្យល់ពិពណ៌នាអំពីបណ្ណសារ សកម្មភាពសិក្ខាសាលា និងការពិភាក្សាអំពីវិធីសាស្ត្រ)។ នៅដំណាក់កាលបន្ទាប់ មជ្ឈមណ្ឌលខេមរសិក្សា នឹងធ្វើការបោះពុម្ពលើកទីពីរក្នុងទម្រង់ផ្សេង ដើម្បីឱ្យសិក្ខាកាមទទួលបានបទពិសោធន៍ នៃការបោះពុម្ពផ្សាយបន្ថែម និងផ្សព្វផ្សាយការងាររបស់ខ្លួនទៅកាន់ទស្សនិកជនឱ្យកាន់តែទូលំទូលាយ។

## លក្ខខណ្ឌក្នុងការដាក់ពាក្យចូលរួម៖

- អាចរៀបចំឯកសារអានបឋមមួយចំនួនមុននឹងចូលរួមសិក្ខាសាលា ដើម្បីពង្រឹងបរិយាកាសសិក្ខាសាលាឱ្យកាន់តែទាក់ទាញ។
- ត្រូវមានចំណូលចិត្តក្នុងការបង្កើតគម្រោង តាមរយៈមធ្យោបាយនានា
- ត្រូវចេះធ្វើការជាក្រុម
- អាចប្រើប្រាស់ភាសាអង់គ្លេស ដោយមូលហេតុថាផ្នែកមួយចំនួននៃសិក្ខាសាលា និងបំណិនឯកសារខ្លះ តម្រូវឱ្យប្រើប្រាស់ភាសាអង់គ្លេស
- អាចចូលរួមសិក្ខាសាលាយ៉ាងសកម្មនិងទៀងទាត់។

- អាចចូលរួមចំណែកក្នុងការធ្វើឯកសារសម្រាប់ការបោះពុម្ពផ្សាយ (ផ្នែកនេះតម្រូវឱ្យសិក្ខាកាមអាចចំណាយពេលច្រើនខែ)។

## របៀបដាក់ពាក្យចូលរួម៖

សម្រាប់បេក្ខជនដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងសិក្ខាសាលានេះ ត្រូវផ្ញើ ប្រវត្តិរូបសង្ខេប (CV) (អតិបរមា ២ ទំព័រ) និងលិខិតលើកទឹកចិត្ត (motivation letter) (អតិបរមា ១ ទំព័រ) ពន្យល់ពីមូលហេតុដែលអ្នកមានចំណាប់អារម្មណ៍ក្នុងការចូលរួមសិក្ខាសាលា និងអ្វីដែលអ្នករំពឹងទុកពីសិក្ខាសាលា។

សូមចុចទីនេះដើម្បីដាក់ពាក្យ៖ https://khmerstudies.org/repurposing-phnompenh-application-form/